# កម្មវិធីសេវាគាំពារនៅផ្ទះ (IHSS)

## ទម្រង់ជ្រើសរើសអ្នកផ្តល់សេវាដោយអ្នកទទួលសេវា

**សេចក្តីណែនាំ៖**

- សូមប្រើទឹកប៊ិចព៌ណខ្មៅ ឬខៀវ។ សូមអក្សរព័ត៌មានជាអក្សរធំឲ្យបានច្បាស់។
- អ្នក (ឬតំណាងពេញសិទ្ធិរបស់អ្នក) ត្រូវតែបំពេញផ្នែក A នៃទម្រង់នេះ ដើម្បីឲ្យខោនធីដឹងថាតើអ្នកណា ដែលអ្នកបានជ្រើសរើសឲ្យផ្តល់សេវាដែលបានអនុញ្ញាតឲ្យផ្តល់ដល់អ្នក។
- ប្រសិនបើអ្នកមានអ្នកផ្តល់សេវាច្រើននាក់ អ្នកត្រូវតែបំពេញទម្រង់ដោយឡែក សម្រាប់បុគ្គលម្នាក់ៗ ដែលនឹងផ្តល់សេវា ដែលបានអនុញ្ញាតឲ្យផ្តល់ដល់អ្នក។
- អ្នកត្រូវតែចុះហត្ថលេខាទទួលស្គាល់ ក្នុងផ្នែក C នៃទម្រង់នេះ។
- សូមបញ្ជូនទម្រង់នេះ ដែលបានបំពេញរួច និងចុះហត្ថលេខារួច មកឲ្យខោនធីវិញ។ ខោនធីនឹងរក្សាទុកទម្រង់ច្បាប់ដើម ហើយប្រគល់ច្បាប់ចម្លងដល់អ្នក។

| ផ្នែក A. ការជ្រើសរើសអ្នកផ្តល់សេវាដោយអ្នកទទួលសេវា | | |
|---|---|---|
| 1. | ឈ្មោះអ្នកទទួលសេវា៖ | |
| 2. | ករណី IHSS របស់ខោនធីលេខ៖ | |
| 3. | ឈ្មោះអ្នកផ្តល់សេវា៖ | |
| 4. | អាសយដ្ឋានអ្នកផ្តល់សេវា៖ | |
| | ទីក្រុង រដ្ឋ លេខកូដ ZIP៖ | |
| 5. | លេខទូរស័ព្ទអ្នកផ្តល់សេវា៖ | |
| 6. | ថ្ងៃខែឆ្នាំកំណើតរបស់អ្នកផ្តល់សេវា៖ | |
| 7. | លេខសន្តិសុខសង្គម* របស់អ្នកផ្តល់សេវា៖ | |
| 8. | ភេទអ្នកផ្តល់សេវា (សូមគូសក្នុងប្រអប់)៖ | ☐ ប្រុស ☐ ស្រី |
| 9. | ទំនាក់ទំនងរបស់អ្នកផ្តល់សេវា ជាមួយនឹងអ្នកទទួលសេវា (ប្រសិនបើមាន)៖ | ☐ ឪពុកម្តាយ ☐ កូន ☐ ប្តី/ប្រពន្ធ/ដៃគូ<br>☐ អ្នកចាត់តែងដោយតុលាការ ☐ អាណាព្យាបាល<br>☐ ផ្សេងទៀត ______________ |
| 10. | ថ្ងៃចាប់ផ្តើមរបស់អ្នកផ្តល់សេវា៖ | |

*ចំណាំ៖ ការប្រមូលលេខសន្តិសុខសង្គម គឺតម្រូវដោយច្បាប់គ្រប់គ្រង និងកែទម្រង់អន្តោប្រវេសន៍ឆ្នាំ 1986 ច្បាប់សាធារណៈ 99-603 (8 USC 1324a) ក្នុងគោលបំណងផ្ទៀងផ្ទាត់អត្តសញ្ញាណបុគ្គល និងអនុញ្ញាតឲ្យធ្វើការនៅក្នុងសហរដ្ឋអាមេរិក។

ខ្ញុំជ្រើសរើសបុគ្គល មានឈ្មោះខាងលើ ឲ្យធ្វើជាអ្នកផ្តល់សេវា IHSS របស់ខ្ញុំ។ បុគ្គលនេះនឹងផ|តល់សេវាមួយចំនួន ឬទាំងអស់ ដែលបានអនុញ្ញាតដោយខោនធី។

## ផ្នែក B. ការព្រមព្រៀងរបស់អ្នកទទួលសេវា

**ខ្ញុំយល់ដឹង និងព្រមព្រៀងថា៖**

- បុគ្គល ដែលខ្ញុំបានជ្រើសរើសឲ្យធ្វើជាអ្នកផ្តល់សេវារបស់ខ្ញុំ មិនអាចទទួលបានប្រាក់ឈ្នួលពីរដ្ឋសហព័ន្ធនិង/ឬរដ្ឋ សម្រាប់ ការផ្តល់សេវាដល់ខ្ញុំឡើយ រហូតដល់ទាល់តែគាត់បានបំពេញរួចរាល់នូវគ្រប់លក្ខខណ្ឌចុះឈ្មោះអ្នកផ្តល់សេវាទាំងអស់។ លក្ខខណ្ឌទាំងនេះ រួមបញ្ចូលទាំងការបំពេញ ការចុះហត្ថលេខា និងការប្រគល់មកវិញ (ដោយផ្ទាល់) នូវទម្រង់ចុះឈ្មោះអ្នកផ្តល់សេវា (SOC 426) ការផ្តិតស្នាមម្រាមដៃ និងការគ្មានជាប់បទល្មើសដែលធ្វើឲ្យបាត់បង់លក្ខណៈសម្បត្តិ តាមរយៈការឆែកប្រវត្តិទោសទណ្ឌ ការបញ្ចប់វគ្គតម្រង់ទិសអ្នកផ្តល់សេវា និងការប្រគល់មកវិញនូវទម្រង់កិច្ចព្រមព្រៀងចុះឈ្មោះអ្នកផ្តល់សេវា ដែលបានចុះហត្ថលេខារួច (SOC 846) ។

- ខោនធី នឹងផ្ញើលិខិតជូនដំណឹងមកខ្ញុំ ដែលប្រាប់ខ្ញុំថាតើ បុគ្គល ដែលខ្ញុំបានជ្រើសរើសឲ្យធ្វើជាអ្នកផ្តល់សេវារបស់ខ្ញុំ មិនបានបំពេញនូវលក្ខខណ្ឌចុះឈ្មោះអ្នកផ្តល់សេវា ឬក៏ថាតើ គាត់មិនមានសិទ្ធិធ្វើជាអ្នកផ្តល់សេវា IHSS ឬយ៉ាងណា។

- ប្រសិនបើខ្ញុំជ្រើសរើសយកបុគ្គលនេះឲ្យផ្តល់សេវាដល់ខ្ញុំ មុនពេលគាត់ចុះឈ្មោះជាមួយអ្នកផ្តល់សេវា IHSS ហើយខោនធីបានផ្ញើលិខិតជូនដំណឹងប្រាប់ខ្ញុំថា គាត់មិនមានសិទ្ធិផ្តល់សេវា IHSS នោះ ខ្ញុំនឹងចំណាយប្រាក់ផ្ទាល់ខ្លួនបង់កម្រៃសេវាឲ្យគាត់ចំពោះសេវាដែលគាត់បានផ្តល់ឲ្យខ្ញុំ មុនពេលគាត់ត្រូវបានកំណត់ថា គ្មានសិទ្ធិធ្វើជាអ្នកផ្តល់សេវា និងចំពោះសេវា ដែលគាត់ផ្តល់ ក្រោយពីខោនធីបានជូនដំណឹងខ្ញុំថា គាត់គ្មានសិទ្ធិធ្វើជាអ្នកផ្តល់សេវា។

- ទាំងខោនធី ឬរដ្ឋ នឹងមិនទទួលខុសត្រូវចំពោះការទាមទារ និង/ឬ ការខាតបង់ ដែលបង្កឡើងដោយបុគ្គលមានឈ្មោះខាងលើ ដែលខ្ញុំបានជ្រើសរើសជួលឲ្យធ្វើជាអ្នកផ្តល់សេវា IHSS របស់ខ្ញុំ។ ខ្ញុំយល់ព្រមការពាររដ្ឋ និងខោនធី មន្ត្រី ភ្នាក់ងារ និងបុគ្គលិករបស់រដ្ឋ និងខោនធី និងទទួលខុសត្រូវចំពោះការទាមទារ និង/ឬការខាតបង់ដែលកើតឡើងចំពោះបុគ្គលណាក៏ដោយ ដែលបង្កឡើងដោយបុគ្គលមានឈ្មោះខាងលើ ដែលខ្ញុំបានជ្រើសរើសជួលឲ្យធ្វើជាអ្នកផ្តល់សេវា IHSS របស់ខ្ញុំ។

- ខោនធី អាចផ្តល់ព័ត៍មានអំពីសេវា ដែល បានអនុញ្ញាតរបស់ខ្ញុំ និងចំនួនម៉ោងសេវាទៅឲ្យបុគ្គលដែលខ្ញុំបានជ្រើសរើសជាអ្នកផ្តល់សេវារបស់ខ្ញុំ។ ខោនធីនឹងផ្ញើទៅឲ្យអ្នកផ្តល់សេវារបស់ខ្ញុំ នូវលិខិតជូនដំណឹងអ្នកផ្តល់សេវា IHSS អំពីចំនួនម៉ោង និងសេវា ដែលបានអនុញ្ញាតរបស់អ្នកទទួលសេវា (SOC 2271) ។

- ចំនួនម៉ោងសរុបប្រចាំខែដែលបានអនុញ្ញាតរបស់ខ្ញុំ នឹងត្រូវចែកជា 4 ដើម្បីកំណត់<u>ចំនួនម៉ោងអតិបរមាប្រចាំសប្តាហ៍</u>របស់ខ្ញុំ។ ចំនួនម៉ោងអតិបរមាប្រចាំសប្តាហ៍ គឺជាខ្សែបន្ទាត់ណែនាំប្រាប់ខ្ញុំអំពីចំនួនម៉ោងច្រើនបំផុត ដែលអ្នកផ្តល់សេវារបស់ខ្ញុំអាចធ្វើការឲ្យខ្ញុំបាន ក្នុងអំឡុងមួយសប្តាហ៍ការងារ។ ប៉ុន្តែ ដោយសារក្នុងខែភាគច្រើន មានរយៈពេលវែងជាង 4 សប្តាហ៍ ខ្ញុំនឹងធ្វើការជាមួយនឹងអ្នកផ្តល់សេវារបស់ខ្ញុំ ដើម្បីបែងចែកចំនួនម៉ោងរបស់គាត់ ក្នុងខែនោះ ដើម្បីធានាថា ខ្ញុំទទួលបានចំនួនម៉ោងសេវាទាំងអស់ដែលខ្ញុំត្រូវការ នៅក្នុងខែនោះ។

- ពេលខ្លះ ខ្ញុំអាចត្រូវការឲ្យអ្នកផ្តល់សេវារបស់ខ្ញុំធ្វើការច្រើនជាងចំនួនម៉ោងអតិបរមាប្រចាំសប្តាហ៍របស់ខ្ញុំ។ ខ្ញុំ ត្រូវតែស្នើសុំការឯកភាពពីខោនធី ដើម្បីកែតម្រូវចំនួនម៉ោងអតិបរមាប្រចាំសប្តាហ៍របស់ខ្ញុំ តែប្រសិនបើ ការផ្លាស់ប្តូរតម្រូវឲ្យអ្នកផ្តល់សេវារបស់ខ្ញុំ ត្រូវធ្វើការ៖

    1. បន្ថែមម៉ោង ក្នុងមួយខែ ច្រើនជាងចំនួនម៉ោងដែលគាត់ធ្វើការជាធម្មតា។

2. ច្រើនជាង 40 ម៉ោងឲ្យខ្ញុំ ក្នុងមួយសប្តាហ៍ការងារ ប្រសិនបើចំនួនម៉ោងអតិបរមាប្រចាំសប្តាហ៍របស់ខ្ញុំ គឺ 40 ម៉ោង ឬតិចជាងនេះ ក្នុងមួយសប្តាហ៍ការងារ។

- ប្រសិនបើខ្ញុំមិនទទួលការឯកភាពទេនោះ អ្នកផ្តល់សេវារបស់ខ្ញុំនឹងទទួលបានលិខិតជូនដំណឹងអំពីការបំពាន ចំពោះការធ្វើការលើសចំនួនម៉ោងអតិបរមាប្រចាំសប្តាហ៍របស់ខ្ញុំ។

- ខ្ញុំ**មិន**អាចអនុញ្ញាតឱ្យអ្នកផ្តល់សេវារបស់ខ្ញុំធ្វើការលើសចំនួនម៉ោងសរុបប្រចាំខែដែលបានអនុញ្ញាតរបស់ខ្ញុំឡើយ។ ដូច្នេះ នៅពេលខ្ញុំអនុញ្ញាតឲ្យអ្នកផ្តល់សេវារបស់ខ្ញុំធ្វើការម៉ោងបន្ថែមក្នុងមួយសប្តាហ៍ ខ្ញុំត្រូវតែឲ្យអ្នកផ្តល់សេវាខ្ញុំធ្វើការតិចម៉ោងជាងមុន ក្នុងសប្តាហ៍ផ្សេងទៀតក្នុងខែនោះ។

- ប្រសិនបើអ្នកផ្តល់សេវារបស់ខ្ញុំធ្វើការឲ្យអ្នកទទួលសេវាផ្សេងទៀត ចំនួនម៉ោងអតិបរមា ដែលគាត់អាចទាមទារបាន ក្នុងមួយសប្តាហ៍ការងារ សម្រាប់អ្នកផ្តល់សេវាទាំងអស់រួមគ្នា គឺមានចំនួន 66 ម៉ោង។ **ខ្ញុំត្រូវតែកំណត់កាលវិភាគការងារឲ្យអ្នកផ្តល់សេវារបស់ខ្ញុំ ដើម្បីកំណត់ចំនួនម៉ោងអតិបរមា ដែលគាត់នឹងធ្វើការឲ្យខ្ញុំ ក្នុងសប្តាហ៍នីមួយៗ ដើម្បីធានាថា គាត់មិនធ្វើការលើសពី 66 ម៉ោង ក្នុងមួយសប្តាហ៍ការងារទេ។** ខ្ញុំនឹងទទួលបានលិខិតជូនដំណឹងអ្នកទទួលសេវាអំពីចំនួនម៉ោងអតិបរមាប្រចាំសប្តាហ៍ (SOC 2271A) ដែលនឹងរួមបញ្ចូលនូវព័ត៌មានស្តីពីចំនួនម៉ោងអតិបរមាប្រចាំសប្តាហ៍របស់ខ្ញុំ ដើម្បីឲ្យខ្ញុំអាចប្រើដើម្បីកំណត់កាលវិភាគការងារឲ្យអ្នកផ្តល់សេវារបស់ខ្ញុំ។ ដើម្បីធ្វើការកំណត់កាលវិភាគបាន អ្នកផ្តល់សេវារបស់ខ្ញុំត្រូវតែប្រាប់ខ្ញុំអំពីចំនួនម៉ោង ដែលគាត់អាចធ្វើការឲ្យខ្ញុំបាន ក្នុងសប្តាហ៍ការងារនីមួយៗ។ ប្រសិនបើអ្នកផ្តល់សេវារបស់ខ្ញុំមិនអាចធ្វើការបានគ្រប់ចំនួនម៉ោងទាំងអស់របស់ខ្ញុំដែលបានអនុញ្ញាត នោះខ្ញុំនឹងត្រូវជួលអ្នកផ្តល់សេវាបន្ថែម។ **ប្រសិនបើខ្ញុំត្រូវការជំនួយក្នុងការស្វែងរក និងជ្រើសរើសអ្នកផ្តល់សេវាផ្សេងទៀត ខ្ញុំអាចទូរស័ព្ទទៅអាជ្ញាធរ IHSS នៃខោនធីរបស់ខ្ញុំ ដើម្បីទទួលបានអ្នកផ្តល់សេវាពីបញ្ជីឈ្មោះអ្នកផ្តល់សេវា ឬទៅការិយាល័យ IHSS នៃខោនធីរបស់ខ្ញុំ។**

- ខោនធីនឹងផ្ញើលិខិតជូនដំណឹងមកឱ្យខ្ញុំ រៀងរាល់ពេលដែលអ្នកផ្តល់សេវារបស់ខ្ញុំបានបំពាន។ ប្រសិនបើអ្នកផ្តល់សេវារបស់ខ្ញុំបានបំពានចំនួនបីលើក គាត់នឹងត្រូវព្យួរមិនឲ្យផ្តល់សេវា IHSS សម្រាប់រយៈពេលបីខែ។ ប្រសិនបើគាត់បំពានបន្ថែមទៀត បន្ទាប់ពីត្រូវបានអនុញ្ញាតឲ្យផ្តល់សេវាវិញ ក្រោយរយៈពេលព្យួរបីខែនោះ គាត់នឹងត្រូវបញ្ឈប់ឋានៈជាអ្នកផ្តល់សេវា សម្រាប់រយៈពេលមួយឆ្នាំ។

## ផ្នែក C. ការទទួលស្គាល់របស់អ្នកទទួលសេវា

**ខ្ញុំយល់ដឹង និងយល់ព្រមអនុវត្តតាមលក្ខខណ្ឌតម្រូវទាំងអស់ ដែលចែងក្នុងទម្រង់នេះ។**

| | |
|---|---|
| ហត្ថលេខាអ្នកទទួលសេវា៖ | កាលបរិច្ឆេទ៖ |
| ឈ្មោះអក្សរធំ៖ | |
| ហត្ថលេខារបស់តំណាងពេញសិទ្ធិ៖ | កាលបរិច្ឆេទ៖ |
| ឈ្មោះអក្សរធំ៖ | |

**សម្រាប់ខោនធីប្រើប្រាស់ប៉ុណ្ណោះ**

| | |
|---|---|
| ឈ្មោះបុគ្គលិក៖ | កាលបរិច្ឆេទ៖ |